អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ (PRD)

ACIAR

aciar.gov.au

# គន្ធា និងគោរីករាយ

# KUNTHEA & THE HAPPY COW



Australian Government

Australian Centre for International Agricultural Research

ស្ទេហ្វាន់ ប៊ិកណា

By: Stephan Bognar

មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ១៩៨២ ដោយច្បាប់របស់រដ្ឋសភាអូស្ត្រាលី។ មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ជាផ្នែកមួយនៃកម្មវិធីសហប្រតិបត្តិការ សម្រាប់ការអភិវឌ្ឍអន្តរជាតិនៃប្រទេសអូស្ត្រាលី ដែលមានបេសកកម្ម ធ្វើឲ្យជោគជ័យនូវប្រព័ន្ធកសិកម្ម ដែលផ្តល់ផលច្រើន និង មាននិរន្តភាព សម្រាប់ជាប្រយោជន៍នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអូស្ត្រាលី។ វាផ្តល់អាទិភាពដល់ការស្រាវជ្រាវ ដែលសហការគ្នា រវាងអ្នកស្រាវជ្រាវនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និង អ្នកស្រាវជ្រាវប្រទេសអូស្ត្រាលី ដែលជាប្រទេសមានសមត្ថភាពពិសេសខាងសិក្សាស្រាវជ្រាវលើវិស័យកសិកម្ម។ វាក៏គ្រប់គ្រងនូវការចូលរួមចំណែករបស់ប្រទេសអូស្ត្រាលី ទៅលើមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិផងដែរ។ ការប្រើប្រាស់ឯកសារ ឬឈ្មោះពាណិជ្ជនេះ មិនរាប់បញ្ចូលថា ជាការគាំទ្រ ឬក៏ជាការរើសអើងនឹងស្នាដៃរបស់មជ្ឈមណ្ឌលឡើយ។

**កម្រងឯកលេខនារបស់ ACIAR**

សៀវភៅទាំងនេះមានបញ្ចូលលទ្ធផលនៃការស្រាវជ្រាវដំបូង ដែលឧបត្ថម្ភដោយមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ឬឯកសារដែលទាក់ទងនឹង ការស្រាវជ្រាវ និងទិសដៅនៃការអភិវឌ្ឍរបស់ ACIAR។ កម្រងសៀវភៅនេះត្រូវបានចែកចាយជាលក្ខណៈអន្តរជាតិ ដែលសង្កត់ធ្ងន់ទៅលើប្រទេសកំពុងអភិវឌ្ឍន៍។

**© មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ២០១៧**

សៀវភៅនេះត្រូវបានរក្សាសិទ្ធិ។ ក្រៅពីការប្រើប្រាស់ណាមួយដែលត្រូវបានអនុញ្ញាត ដូចមានចែងក្នុងច្បាប់រក្សាសិទ្ធិ ឆ្នាំ ១៩៨៦។ គ្មានផ្នែកណាមួយនឹងអាចត្រូវ បានយកទៅផលិតសារឡើងវិញតាមមធ្យោបាយណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពី ACIAR ដែលមានអាស័យដ្ឋាន GPO Box 1571, Canberra ACT 2601, Australia, aciar@aciar.gov.au

**សហការបោះពុម្ពដោយ ACIAR និង អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ (PRD)**

PRD គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានបង្កើតឡើងនិងចុះបញ្ជីជាផ្លូវការជាមួយក្រសួងមហាផ្ទៃ នៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៧។ បេសកកម្មរបស់ PRD គឺដើម្បីផ្តល់ឲ្យកុមារី និង ស្ត្រីនៅតាមជនបទនាភាគពាយព្យនៃប្រទេសកម្ពុជា ឲ្យមានជំនាញនិងការគាំទ្រដែលចាំបាច់ដើម្បី កសាងសហគមន៍ ដែលមានសុខភាពល្អ ដោយសន្តិភាព និងការបង្រួបបង្រួមសហគមន៍។

មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ និង អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ
Canberra, ACT. ៤៨ទំព័រ
ACIAR Monograph no. MN164
ISSN 1031-8194 (បោះពុម្ព)
ISBN 978 1 925746 05 1(អ៊ីនធើណែត)

**គន្ធា និង គោរីករាយ ២០១៧**

និពន្ធដោយ : លោក ស្ទេហ្វាន់ ប៊ិកណា
បកប្រែជាភាសាខ្មែរដោយ: លោក អ៊ួម ណារ៉ប
អ្នកស្រី យឹម ម៉ានីកា និង លោក ប៉ែន មីរ៉ាន់ដា
បោះពុម្ពដោយ : រោងពុម្ព Grand Arts (E: grandarts2@gmail.com) ភ្នំពេញ
រចនា និង រូបភាពដោយ : សឹង្ហ មករា

The Australian Centre for International Agricultural Research (ACIAR) was established in June 1982 by an Act of the Australian Parliament. ACIAR operates as part of Australia's international development cooperation program, with a mission to achieve more productive and sustainable agricultural systems for the benefit of developing countries and Australia. It commissions collaborative research between Australian and developing country researchers in areas where Australia has special research competence. It also administers Australia's contribution to the International Agricultural Research Centers. Where trade names are used this constitutes neither endorsement of nor discrimination against any product by ACIAR.

**ACIAR MONOGRAPH SERIES**

This series contains the results of original research supported by ACIAR, or material deemed relevant to ACIAR's research and development objectives. The series is distributed internationally, with an emphasis on developing countries.

© Australian Centre for International Agricultural Research (ACIAR) 2017
This work is copyright. Apart from any use as permitted under the Copyright Act 1968.

No part may be reproduced by any process without prior written permission from ACIAR,
GPO Box 1571, Canberra ACT 2601, Australia, aciar@aciar.gov.au

Co-published by ACIAR and Partners for Rural Development (PRD) Cambodia
PRD is a Cambodian non-governmental organization (NGO). It officially received its NGO registration license from the Cambodian Ministry of Interior in January 2017. PRD's mission is to provide rural girls and women in northwestern Cambodia with the skills and support needed to build healthy, peaceful and inclusive communities.

Australian Centre for International Agricultural Research and Partners for Rural Development: Canberra, ACT. 48 pages.
ACIAR Monograph no. MN164
ISSN 1031-8194
ISBN 978 1 925746 05 1

**Kunthea and The Happy Cow 2017**
**Author:** Stephan Bognar
**Khmer Translation:** Narap Ourm, Manika Yim and Miranda Pen
**Printed by:** Grand Arts Printing House,E: grandarts2@gmail.com
**Designed and Illustration by**: Makara SINGH



ព្រះសូរិយារះចែងចាំងនៅលើផ្ទៃមេឃពណ៌ខៀវខ្ចីដ៏ធំល្វឹងល្វើយ។ គន្ធាបានបញ្ចប់ការសិក្សា ហើយវិលត្រឡប់មកផ្ទះវិញ ដែលស្ថិតនៅតំបន់ជនបទដ៏តូចមួយហៅថា "សំឡូត" ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ នាងបានទៅសិក្សានៅប្រទេសឥណ្ឌូនេស៊ី រយៈពេលមួយឆ្នាំ។

With the sun shining high in the big blue sky, Kunthea was finally returning home to her small rural village called Samlout in the Kingdom of Cambodia. She had been studying in Indonesia for one year.





គន្ធាជាសិស្សដំបូងបំផុតនៅក្នុងសាលារបស់នាង ដែលទទួលបានអាហារូបករណ៍ ទៅសិក្សានៅប្រទេសឥណ្ឌូនេស៊ី ហើយនាងក៏ជាមនុស្សទីមួយនៅក្នុងភូមិ ដែលបានចាកចេញទៅសិក្សានៅក្រៅប្រទេសផងដែរ។ ដូច្នេះហើយ នាងទទួលអារម្មណ៍ថានាងប្រៀបដូចជាវីរនារីប្រចាំភូមិម្នាក់អ៊ីចឹង។

Kunthea was the first student in her school to win a student exchange scholarship. She was also the first person from her entire village to travel to another country. She felt like a real local hero.



នៅពេលដែលគន្ធាឡើងលើរថយន្តក្រុងចាស់ពណ៌បៃតង នាងមានអារម្មណ៍រំភើបខ្លាំង ប៉ុន្តែក៏មានការនឿយហត់ណាស់ដែរ។ ការធ្វើដំណើរតាមយន្តហោះ ពីប្រទេសឥណ្ឌូនេស៊ីមកប្រទេសកម្ពុជា ត្រូវចំណាយពេលយូរហើយពោរពេញទៅដោយសំឡេងអ៊ូរអរ អឺងកង ពីព្រោះសិស្សទាំងអស់សប្បាយរីករាយក្នុងការធ្វើដំណើរ ត្រឡប់មកផ្ទះវិញ។

When Kunthea boarded the old green bus at the airport, she was very excited, but also tired. The airplane ride from Indonesia to Cambodia had been long and noisy because of all the happy students returning home.





ភ្លាមៗនោះ បន្ទាប់ពីគន្ធាដើរទៅរកកន្លែងអង្គុយរបស់នាងក្នុងរថយន្តក្រុងរួចហើយ នាងក៏ផ្អែកក្បាលទៅលើបង្អួចរថយន្ត។ នាងប្រឹងបើកភ្នែកដើម្បីមើលទេសភាព ប៉ុន្តែចុងក្រោយនាងក៏បានលង់លក់ជាមួយនឹងសំឡេងម៉ាស៊ីនរថយន្តដែលឮសូរ ងឺត ងឺត។

As soon as Kunthea found her seat on the bus, she rested her head against the window. She tried so hard to keep her eyes open, but she finally fell asleep listening to the sounds of the squeaky bus engine.



នៅពេលដែលរថយន្តក្រុងចាស់ពណ៌បៃតង បើកយឺតៗនៅលើផ្លូវទៅកាន់ភូមិរបស់នាង គន្ធាស្រមៃឃើញគ្រួសាររបស់នាង មិត្តភក្តិ រួមទាំងសាន់នី និងចម្ប៉ា។ សាន់នីគឺជាខ្លាឃ្មុំរស់នៅក្នុងជាយព្រៃ ជិតចម្ការរបស់គន្ធា។ ចម្ប៉ាគឺជាគោតែមួយគត់ របស់គ្រួសារនាង។ គន្ធាបានប្រទះឃើញចម្ប៉ា នៅក្នុងព្រៃតាំងពីវានៅជាកូនគោតូចនៅឡើយ។

As the old green bus slowly made its way to her village, Kunthea dreamed about her family and friends, including Mr. Sunny and Mr. Champa. Mr. Sunny was a sun bear who lived at the edge of the forest near Kunthea's family farm. Mr. Champa was the family's only cow. Kunthea found Mr. Champa alone in the forest when he was just a baby calf.

នាងពិតជានឹកពួកវាខ្លាំងណាស់ ជាពិសេសនៅពេលដែលនាងបានឃើញពីជីវិតសត្វព្រៃ និង ព្រៃឈើដ៏ស្រស់ស្អាត រួមទាំងហ្វូងគោដែលមានសុខភាពល្អ ហើយរស់នៅយ៉ាងសប្បាយរីករាយ ក្នុងកសិដ្ឋានរបស់ម្ចាស់ផ្ទះដែលនាងស្នាក់នៅជាមួយនៅប្រទេសឥណ្ឌូនេស៊ី។

She really missed Mr. Sunny and Mr. Champa, especially when she saw all the beautiful wildlife in the forests and the healthy cows living happily on her host family's farm in Indonesia.



រំពេចនោះ អ្នកបើកបររថយន្តស្រែកឡើងថា៖ ”មកដល់សំឡូតហើយ! អ្នកទាំងអស់គ្នាអញ្ជើញចុះ!” គន្ធាដឹងខ្លួន បើកភ្នែកឡើង ក៏ឃើញថាមកដល់ភូមិល្មម។ នាងម្នីម្នាចុះពីលើឡាន ហើយចេញទៅរកក្រុមគ្រួសាររបស់នាង ដែលកំពុងឈររង់ចាំ។ ឪពុកម្ដាយនាងជាមនុស្សដំបូងដែលបានមកដល់ ស្ទុះមកឱបនាង។

The bus driver suddenly shouted “Final Stop-Samlout. Everyone out!” Kunthea woke up. Her bright brown eyes shone as she saw that she had arrived at her village. She quickly jumped up from her seat and off the bus. Kunthea’s whole family was waiting for her. Her mother and father were the first ones to reach out and hug her.





ពួកគាត់ឱបនាងយ៉ាងខ្លាំង ធ្វើឲ្យនាងសឹងតែពិបាកដកដង្ហើម។ បន្ទាប់មក ប្អូនប្រុសតូច និងប្អូនស្រីរបស់នាង ក៏ហក់ មកតោងកនាង។ ពួកគេដួលទៅលើដីពោរពេញទៅដោយស្នាមញញឹម និង សំណើចក្អាកក្អាយ ហើយលើកដៃឡើងលើ ហាក់បីដូចជាកូនទាដែលត្រដាងស្លាបនៅក្នុងស្រះទឹក រៀបនឹងហើរឡើង។ ទីបំផុតគន្ធាបានមកដល់ផ្ទះវិញ ហើយ ។

They gave her such a big hug that Kunthea could hardly breathe. After her parents let her go, Kunthea’s little brother and younger sister jumped on her. They all fell to the ground smiling, laughing and lifting their arms to the sky like little ducklings lifting their wings in the village pond trying to fly. Kunthea was finally home.





នៅពេលដែល គន្ធា និងគ្រួសារ ធ្វើដំណើរពីចំណតរថយន្តទៅផ្ទះវិញ គន្ធាមានអារម្មណ៍ថា គ្រប់យ៉ាង
នៅក្នុងភូមិ មានសភាពខុសប្លែកពីមុន។ ខែសីហាទៅហើយ មើលទៅដីប្រេះស្ងួត
ហួតហែង។ នៅលើមេឃមានពពកតិចតួច រីឯដើមឈើលើភ្នំក៏តិចដែរ។

As Kunthea and her family walked home from the bus stop, Kunthea felt that there was something different in the village. It was the month of August and the ground looked very dry. There were few clouds in the sky and fewer trees on the hills.



ជាធម្មតានៅខែសីហា តែងតែមានពពក មានភ្លៀង ហើយមានក្មេងៗហែលទឹកលេងនៅក្នុងស្ទឹង។ ប៉ុន្តែថ្ងៃនេះ
គ្មានក្មេងៗនៅក្នុងស្ទឹងទេ ក៏ព្រោះតែស្ទឹងបានរីងស្ងួតស្ទើរតែគ្មានទឹក។

Usually the month of August was cloudy and rainy with many children playing in the river. Today, however, there were no children playing in the water because the river was almost dry.



“ហ៊ឹម... ទឹកស្ទឹងបាត់ទៅណាអស់ហើយ?” គន្ធាសួរ។ ឪពុករបស់នាង ក្រឡេកមើលទៅស្ទឹង ហើយឆ្លើយថា៖ ”ពួកយើងក៏មិនដឹងច្បាស់ដែរ ហើយកសិករនៅទីនេះក៏មានការព្រួយបារម្ភណ៍អំពីរឿងនេះដែរ។

“Hmmm. Where did all the water go?” asked Kunthea. Her father turned to look at the little river and said, “We are not sure. All the farmers are getting a little worried.



ភ្លៀងមិនបង្អុរ តាំងពីខែវិច្ឆិកាឆ្នាំមុនមកម្ល៉េះ។ ប្រសិនបើនៅតែមិនមានភ្លៀងទៀត ដំណាំពោត និងសណ្តែកសៀង របស់យើង ប្រាកដជាងាប់អស់ជាមិនខាន ហើយក៏គ្មានត្រីនៅក្នុងស្ទឹងទៀតដែរ។” គន្ធាដកដង្ហើមធំ រួចងើយមើលទៅឪពុករបស់នាងទាំងក្រៀមក្រំ។

We haven’t received much rain since last November. If we don’t receive rain very soon, we will lose our crops of soybeans and corn. And, with no water, we won’t have any fish in the river.” Kunthea inhaled deeply and looked up at her father with a very sad face.



ពេលមកដល់ផ្ទះ នាងប្រញាប់ប្រញាល់រត់ទៅខាងក្រោយផ្ទះដោយសង្ឃឹមថា ចម្ប៉ា និង ខ្លាឃ្មុំសាន់នី នឹងមកទទួលស្វាគមន៍នាង។ ប៉ុន្តែពេលទៅដល់ខាងក្រោយផ្ទះ នាងឈប់ទ្រឹង ភ្ញាក់ផ្អើលទៅនឹងទិដ្ឋភាពដែលបានឃើញ។ នាងហាមាត់រកនិយាយ តែនិយាយមិនចេញ។ មុនពេលនាងចាកចេញទៅឥណ្ឌូនេស៊ី គ្រួសាររបស់នាងមានចម្ការដ៏ស្រស់ស្អាតដែលមានមាន់ ស្រែកក្រុកៗ មានចម្ប៉ា ស្រែកម៉ូៗ ហើយទំពាអៀង

When they arrived home, Kunthea ran to her backyard to see if Mr. Champa and Mr. Sunny the bear would welcome her home. But as soon as Kunthea turned around the corner of her house, she stopped. She opened her mouth wide, but no words came out. She just stood and stared at the landscape. Before she left for Indonesia, her family had a beautiful farm with some chickens that clacked and clucked, Mr. Champa who mooed and chewed,





ចំណែកឯសួនបន្លែវិញមានពណ៌បៃតងដែលមានដើមឈើព័ទ្ធជុំវិញ រួមទាំងកូនស្ទឹងដ៏វែងក្ររៀចក្ររៀនហូរកាត់ចម្ការ ពួកគេ។ ថ្ងៃនេះព្រៃឈើស្ទើរតែបាត់អស់ ស្ទឹងក៏មិនមានទឹក ហើយក៏គ្មានសំឡេងមាន់ក្រុកៗ ស្វែងរកជន្លេនទៀតដែរ។ បន្លែក្នុងសួនបានងាប់អស់។ ចម្ប៉ា ពេលវាឃើញគន្ធា វាងើបក្បាលមើលនាងហើយស្រែកតិចៗថា ម៉ូៗ។ វាឥឡូវមើលទៅស្គមជាងមុន ហើយឯកាណាស់។

and a very colourful veggie garden surrounded by trees and a snake-like river winding through their farm. Today, the forest was almost gone. The river was no longer a river. And there were no more chickens clacking and clucking and searching for worms in the ground. The veggie garden had also died. When Mr. Champa saw Kunthea, he just lifted his head and whispered "Moo Moo." He looked skinny and very lonely.

គន្ធាដើរទៅជិតចម្ប៉ា រួចស្ទាបមុខវា ក្រែងលោវាឈឺ។ វាមិនក្តៅខ្លួនទេ ហើយនាងក៏ស្រែកហៅរកសាន់នីទៀត ក៏មិនឃើញមកដែរ។ ព្រៃកាន់តែរួមតូច ដើមឈើក្នុងព្រៃក៏តិច ប្រហែលជាសាន់នីទៅរកកន្លែងផ្សេងទៀតធ្វើជាជម្រកហើយ។ គន្ធាចាំថា សាន់នីតែងតែបន្លឺសំឡេងតិចៗជាសញ្ញាថា វាត្រូវការព្រៃដែលសំបូរទៅដោយដើមឈើពណ៌បៃតង ដើម្បីការពារខ្លួនពីភ្លៀង និងកំដៅថ្ងៃ។ វាក៏ចូលចិត្តស៊ីក្បាលទឹកឃ្មុំដ៏ផ្អែមឆ្ងាញ់ដែលចេញពីផ្លិតឃ្មុំនៅលើមែកឈើផងដែរ។ ប៉ុន្តែឥឡូវនេះ សាន់នី មិនដឹងទៅណាបាត់ទេ។

Kunthea went to see Mr. Champa and touched his face to see if he was ill. She didn't feel any fever, so she called out for Mr. Sunny, but he didn't come. The forest was so small with so few trees that perhaps Mr. Sunny had to find another forest to make his home. Kunthea remembered that Mr. Sunny always grumbled in a low voice to let her know his forest needed lots of green trees to protect him from the sun and the rain. He also loved to eat the sweet honey from the bees in the trees. But today Mr. Sunny was nowhere to be found.





គន្ធាកត់សម្គាល់ថា មិនត្រឹមតែសាន់នីទេដែលបាត់ទៅ សូម្បីតែសំឡេងសត្វស្លាបច្រៀង ឬសំឡេងឃ្មុំហើរក៏មិនលឺដែរ។ នាងស្រែកឡើងថា “តើសត្វស្លាប និងពពួកឃ្មុំ ក៏ទៅបាត់អស់ដែរឬ?” នាងងើយមើលទៅមេឃគ្មានដុំពពកដែលអាចនាំទឹកភ្លៀងមកសោះ។ ប្រហែលនេះហើយជាមូលហេតុដែលធ្វើឲ្យចម្ប៉ាមិនរីករាយ ព្រោះវាគ្មានមិត្តភក្តិដើម្បីលេងជាមួយ គ្មានទឹកសម្រាប់ងូត និងផឹក ហើយក៏គ្មានរុក្ខជាតិបៃតងស្រស់ៗសម្រាប់ស៊ីទៀតដែរ។ គន្ធាមានអារម្មណ៍ខឹង មិនសប្បាយចិត្ត។ នាងឱបចម្ប៉ាថ្នមៗ ហើយនិយាយថា៖ ”លាសិនហើយ” រួចដើរទៅរកឪពុករបស់នាងដើម្បីសួរនាំអំពីព្រៃឈើ ចម្ការ និងខ្លាឃ្មុំសាន់នី។

Kunthea realized that it was not only Mr. Sunny who was gone. She couldn't hear the birds sing or the bees buzz. “Have the birds and the bees also left?” cried Kunthea. She looked at the open sky. There was not one cloud wanting to drop some rain on her farm. Maybe that's why Mr. Champa looked so sad. He had no friends to play with and no water to bathe and drink. There were also no crunchy green plants to eat. Kunthea was also sad, and a little angry. With gentle hands, she hugged Mr. Champa and said goodbye. Kunthea marched away, looking for her father to ask about the forest, the farm and, of course, Mr. Sunny the bear.





គន្ធាបានជួបឪពុករបស់នាងនៅផ្ទះអ្នកជិតខាង ដែលកំពុងជួយជួសជុលស្នប់អណ្តូងរបស់អ៊ំស៊ីថា។ វាបានខូចក្នុងពេលដែលអ៊ំស៊ីថាព្យាយាមសប់ទឹកពីអណ្តូង។ កំឡុងពេលរដូវភ្លៀង អណ្តូងស្នប់មានទឹកច្រើន។ ឥឡូវនេះ ដោយសារតែគ្មានភ្លៀង ទឹកកប់យ៉ាងជ្រៅនៅក្នុងដី ដែលធ្វើឲ្យពិបាកក្នុងការសប់ទឹកឡើង។ គន្ធាឃើញឪពុករបស់នាង និង អ៊ំស៊ីថា កំពុងរវល់ នាងមិនចង់រំខានពួកគាត់ ក៏សម្រេចចិត្តទៅជួប សូភី ដែលជាមិត្តរបស់នាង នៅក្នុងសាលា។ ថ្ងៃនេះជាថ្ងៃចុងក្រោយមុនពេលវិស្សមកាលមកដល់។

Kunthea found her father at their neighbour's house trying to help Mr. Sitha fix the pump for the water well. The pump broke down when Mr. Sitha tried to collect water from the well. During the rainy season, the well was always full of clean water. Now, with no rain, the water was so far deep in the ground that the pump was not big enough to pull it up. Kunthea saw that her father and Mr. Sitha were very busy. She didn't want to disturb them so she decided to go visit her friend Sophy at the school. It was the last day of classes before the long summer break.

មុនពេលគន្ធាចេញមករកសូភីនៅសាលារៀន នាងបានដើរជុំវិញចម្ការអ៊ំស៊ីថា។ នាងបានឃើញហ្វូងគោមានសភាពស្ងាត់ស្ងៀម មិនមានកម្លាំងកំហែង ហើយមិនទំពាអៀង ឬក៏ស្រែក ម៉ៗ ដូចពីមុនទេ។ ដើមឈើនៅលើភ្នំក៏បាត់អស់ដែរ ជំនួសដោយចម្ការពោតជាជួរៗវិញ។ ប៉ុន្តែពោតទាំងនោះ មិនមានពណ៌បៃតងស្រស់ល្អទេ បែរជាស្រពោនក្រៀមស្វិតទៅវិញ។ គន្ធាដកដង្ហើមធំ រកកល់ចង់យំ។

Before Kunthea left her father, she walked around Mr. Sitha's farm. She saw that the cows were very silent, not chewing or mooing as they had in the past. The trees on the hills had also disappeared. Instead of a forest, she saw rows and rows of corn. But the crops were not green or gold, just brown and dry. Kunthea sighed and wanted to cry.







សូភីជាមិត្តល្អម្នាក់ក្នុងចំណោមមិត្តភក្តិជិតស្និទ្ធជាច្រើនរបស់គន្ធា។ គន្ធានៅតែចងចាំរឿងរ៉ាវរបស់នាង និងសូភីដែលបានបង្កើតសួនបន្លែ និងចិញ្ចឹមមាន់ជាមួយគ្នាយ៉ាងសប្បាយរីករាយ។ សូភីបានជួយអ្នកភូមិជាច្រើនក្នុងការបង្កើតសួនបន្លែយ៉ាងស្រស់បំព្រង និងដាំបន្លែជាច្រើនមុខ មានដូចជា ការ៉ុត ត្រសក់ និងសណ្តែកបាយ។ សូភីក៏ជាវីរនារីនៅក្នុងភូមិម្នាក់ដែរ។

Sophy was one of Kunthea's best friends. Kunthea still remembered how she and Sophy had had so much fun creating a veggie garden and taking care of the happy chickens. Sophy helped the whole village make beautiful gardens and grow crunchy vegetables, like bright orange carrots, green cucumbers and crispy mung beans. Sophy was also a village hero.



គន្ធារង់ចាំសូភី នៅក្បែរទ្វាររបងសាលា។ នាងចង់ឲ្យសូភីភ្ញាក់ផ្អើល ដូច្នេះហើយនាងក៏ទៅពួននៅពីក្រោយដើមជ្រៃដ៏ធំមួយ។ ខណៈពេលដែលសូភី កំពុងដើរកាត់តាមនោះ គន្ធាក៏ហក់ចេញមកពីក្រោយហើយស្រែកថា៖ ”ខ្ញុំមកវិញហើយ! ខ្ញុំមកវិញហើយ!” សូភីភ្ញាក់ បែរក្រោយ រួចស្ទុះទៅឱបមិត្តល្អរបស់នាង។ ពួកគេញញឹមរីករាយយ៉ាងខ្លាំង។ នៅពេលដែលពួកគេដើរត្រឡប់ពីសាលាទៅផ្ទះវិញជាមួយគ្នា សូភីបន្តរៀបរាប់មិនឈប់ អំពីគ្រួសារ និងមិត្តភក្តិទាំងឡាយរបស់ពួកគេព្រមទាំងរឿងរ៉ាវដែលកើតឡើងក្នុងភូមិបន្ទាប់ពីគន្ធាចាកចេញទៅរៀននៅឥណ្ឌូនេស៊ី។

Kunthea waited for Sophy at the gates of the school. She wanted to surprise her, so she hid behind the village Banyan tree. As soon as Sophy walked past the tree, Kunthea jumped behind her and shouted, “I’m here! I’m here!” Sophy quickly turned around and hugged her best friend. Their smiles were as big as the moon. As they walked from the school to their home, Sophy couldn’t stop talking. She talked about her family, their friends and what happened to their village after Kunthea left for Indonesia.



“ក្រោយពេលដែលឯងចេញទៅ ហើយស្លឹកឈើប្រែក្លាយទៅជាពណ៌លឿងដូចមាស មានបុរសចម្លែកម្នាក់មានមាឌធំ ហើយមាំ បានមកភូមិយើង។ គាត់បានប្រាប់អ្នកភូមិថា ប្រសិនបើយើងចង់បានពោតច្រើនដើម្បីលក់ ពួកយើងត្រូវតែកាប់ព្រៃឈើ ហើយដាំដំណាំលើភ្នំជំនួសវិញ។ គាត់ថា ដីនៅទីនោះល្អសម្រាប់ដាំដំណាំ ហើយទទួលបានទិន្នផលច្រើនដើម្បីលក់មកឲ្យក្រុមហ៊ុនគាត់។ ពេលដែលកសិករមិនជឿគាត់ គាត់បាននិយាយទៀតថា៖ ”មើលន៏! មើលទៅព្រៃឈើទាំងនោះទៅ! ប្រសិនបើដីនៅទីនោះ អាចធ្វើឲ្យដើមឈើទាំងនោះដុះធំលូតលាស់បានល្អ ដូច្នេះ វាក៏អាចឲ្យយើងដាំពោតបានល្អដែរ!”

“After you left and the leaves on the trees turned orange and gold, a strange man came to our village. He was very big and very bold. He told the villagers that if they wanted to sell more corn, they must cut down their forests and plant crops on the hills,” cried Sophy. “He told them that the soil on the hills would be very good for their crops and produce lots of corn to sell to his company. When the farmers didn’t believe him, he said, “Look! Look at the forests! If the soil can produce big and strong trees, it could also produce corn as yellow as gold.”

សូភីនិយាយទៀតថា ចុងក្រោយពួកកសិករក៏យល់ស្របតាមគំនិតរបស់បុរសចម្លែកម្នាក់នោះ។ កសិករខ្លះសម្រេចចិត្តកាប់ឈើដោយពូថៅ ហើយខ្លះទៀតក៏យកភ្លើងមកដុតព្រៃតែម្តង។ សូភីស្រែកឡើងថា៖ “ផ្សែងដែលចេញមកគឺគួរឲ្យខ្លាចខ្លាំងណាស់។ វាមានពណ៌ខ្មៅហើយកខ្វក់ ធ្វើឲ្យអ្នកភូមិជាច្រើនពិបាកក្នុងការដកដង្ហើមហើយធ្លាក់ខ្លួនឈឺ។ ក្រុមគ្រួសារអ្នកភូមិជាច្រើននាក់ ត្រូវទៅព្យាបាលនៅមណ្ឌលសុខភាព សូម្បីតែចម្ប៉ាក៏ត្រូវទៅទទួលការព្យាបាលពីពេទ្យសត្វប្រចាំភូមិដែរ។”

Sophy explained that the farmers finally believed the stranger. Some farmers decided to cut down the trees with axes. Other farmers used fire to burn down the forests. “The smoke from the fire was terrible,” cried Sophy. “The air became so dark and dirty that many of the villagers had trouble breathing and fell ill. Many families had to visit the local health centre for help. Even Mr. Champa needed to see the village animal doctor.”





សូភីពោលតិចៗដោយក្រៀមក្រំថា៖ “បន្ទាប់ពីបាត់បង់ព្រៃឈើអស់ពីលើភ្នំទៅ សត្វព្រៃក៏បាត់អស់ទៅតាមនោះដែរ។ ទីបំផុតពេលដែលភ្លៀងធ្លាក់មក ទឹកភ្លៀងបានហូរច្រោះដីពីលើភ្នំនាំយកដំណាំមកជាមួយគ្នា។ ពួកយើងមិនបានដឹងថា ឫសឈើទាំងនោះជួយទប់ដីលើភ្នំនោះទេ។ ហើយក៏គ្មាននរណាម្នាក់បានប្រាប់យើងពីរឿងនេះដែរ។ បន្ទាប់ពីភ្លៀងរាំង ពួកយើងនាំគ្នាទៅដាំដំណាំម្តងទៀត ប៉ុន្តែស្ទើរតែមិនមានដីសម្រាប់ដាំដុះទេ ឃើញសុទ្ធតែថ្ម។ ដូច្នេះវាពិបាកក្នុងការដាំពោត និងដំណាំផ្សេងៗណាស់។”



Sophy sadly mumbled, “After most of the trees disappeared on the hills, the forest animals also disappeared. When the rains finally arrived, the water rushed down from the top of the hills and washed the soil and crops away! We didn’t know that the roots of the trees can help protect the soil on the hills. No one told us. After the rain stopped we went back to plant the crops. But we found too many rocks, and very little soil on the hills. It was very difficult to plant the corn.”

ក្នុងពេលដែលសូភីកំពុងរៀបរាប់ គន្ធានឹកគិតទៅដល់កសិដ្ឋាននៅប្រទេសឥណ្ឌូនេស៊ី និងការរស់នៅដ៏រីករាយរបស់ហ្វូងគោ ព្រមទាំងសត្វព្រៃ និងព្រៃភ្នំដ៏ស្រស់ស្អាត។ ជាពិសេសនាងនឹកឃើញទៅដល់ អូរ៉េងហ្គូលូ ដែលជាស្វាឪដ៏ធំមួយ រស់នៅលើដើមឈើ។ ជួនកាលនាងឃើញវាពេលព្រះអាទិត្យរៀបលិច ហើយពន្លឺព្រះអាទិត្យបានជះទៅធ្វើឲ្យមុខពណ៌ក្រហមរបស់វាចាំងតាមប្រឡោះមែកឈើ។ សូភីបានស្រែកឡើងថា៖ ”គន្ធា! តើឯងកំពុងស្តាប់ខ្ញុំនិយាយឬអត់ហ្នឹង?” គន្ធាឆ្លើយថា៖ “ចាស! ឲ្យខ្ញុំសុំទោស! ខ្ញុំកំពុងគិតពីកសិដ្ឋាននិងព្រៃភ្នំនៅប្រទេសឥណ្ឌូនេស៊ី។

As Sophy continued to tell the story, Kunthea thought about her farm in Indonesia and about the happy cows and beautiful wildlife in the forests. She especially remembered Mr. Oranguloo, a very big ape who lived in the trees. She would sometimes see Mr. Oranguloo at sunset. His reddish-orange face would always glow through the trees as the sun would slowly go to sleep. Sophy shouted, “Kunthea! Are you listening to me?” “Yes!” replied Kunthea. “I’m sorry. I was just thinking about the farm and forests in Indonesia.



តើឯងដឹងទេថាខ្ញុំបានរស់នៅទីនោះ ដែលជាកន្លែងមានហ្វូងគោប្រកបដោយសុខភាពល្អ ហើយពួកវាសប្បាយរីករាយនឹងការស្រែកម៉ៗ តាំងពីព្រឹករហូតដល់ល្ងាច។ ព្រៃឈើដែលសំបូរទៅដោយដើមឈើក្រាស់ឃ្មឹក មានពណ៌ខៀវស្រងាត់។ ប៉ុន្តែអ្វីដែលល្អបំផុតនោះគឺ ពពួកសត្វព្រៃ។ ពួកវាស្រែកច្រៀងរាំ សប្បាយជាមួយនឹងសំឡេងសត្វល្អិតរាប់លានដែលរស់នៅទីនោះ។ វាដូចជាការប្រគុំតន្ត្រីមួយអ៊ីចឹង! តោះសូភី! ឆាប់ឡើង! ពួកយើងត្រូវតែទៅរក ពូប៊ុនឡា ដែលជាអ្នកជំនាញដាំដើមឈើប្រចាំភូមិរបស់ពួកយើង។”

Did you know that I lived on a farm with cows that were so healthy and happy that they mooed from morning till night. The forests were also full of trees with dark green leaves. But best of all was the wildlife. The animals would sing, shout and dance to the sounds of the millions of insects living in the forests. It was like a music concert. Come on Sophy! Let’s go! We have to find Mr. Bunla, our village tree teacher.”

ពេលពួកគេទៅដល់ផ្ទះរបស់ពូប៊ុនឡា ក៏ឃើញគាត់នៅក្នុងថ្នាលបណ្ដុះកូនឈើ កំពុងនិយាយតិចៗទៅកូនឈើ និងដើមផ្កាដែលព្យួរនៅសំយាបផ្ទះរបស់គាត់។ គន្ធាស្រែកហៅ ”ពូប៊ុនឡា!” រួចរត់សំដៅទៅផ្ទះ របស់គាត់យ៉ាងតក់ក្រហល់ ហើយនិយាយថា៖ ”ពួកយើងត្រូវការឲ្យលោកពូជួយ។ តើលោកពូអាចជួយពួកយើងនាំយកព្រៃឈើត្រឡប់មកវិញបានទេ? ពួកយើងត្រូវការដើមឈើរបស់លោកពូ ទាំងតូចទាំងធំ ហើយនិងរុក្ខជាតិខ្លះទៀត ដែលអាចដាំជាមួយគ្នាបាន។ ពួកយើងត្រូវដាំវាឡើងវិញនៅក្នុងព្រៃ!”

When they reached Mr. Bunla’s house, they found him in his tree nursery softly talking to his plants and trees and all the flowers hanging from the roof. “Mr. Bunla!” cried Kunthea, out of breath as they ran to his house. “We need your help. Can you help us bring back our forests? We need your trees, the big and small, and some plants that will grow with them all. Yes! We need them to replant our forest!”







ស្របពេលដែលគន្ធាសម្រួលដង្ហើមឡើងវិញ នាងក្រឡេកឃើញកូនពីងពាងតូចមួយ កំពុងធ្វើសម្បុកនៅចន្លោះដើមផ្កា។ ដោយក្ដីរំភើបរីករាយ នាងបានចែករំលែកគំនិត ដ៏សំខាន់មួយរបស់នាង៖ ”ព្រៃឈើរបស់យើងត្រូវផ្សារភ្ជាប់ជាមួយដី ជាមួយទឹក ជាមួយចម្ការរបស់យើង។ អ្វីៗគ្រប់យ៉ាងត្រូវតែមានការពាក់ព័ន្ធគ្នា!”

As Kunthea started to catch her breath, she saw a small spider building its spider web between the flowers. She excitedly shared the important thought she had. “Our forest is connected to our soil, which is connected to our water, which is connected to our farm. Everything is connected!”

គន្ធាបន្តពន្យល់ប្រាប់ពូប៊ុនឡា និង សូភី អំពីគ្រប់យ៉ាងដែលនាងបានឃើញ នៅក្នុងកសិដ្ឋាននាប្រទេសឥណ្ឌូនេស៊ី។ សូភីសម្លឹងមើលគន្ធាដោយស្នាមញញឹម និង ងក់ក្បាលយល់ស្រប។ នាងរីករាយណាស់ដែលមិត្តល្អរបស់នាងបានត្រឡប់មកផ្ទះវិញ។

គន្ធា និង សូភីបានជម្រាបលា ពូប៊ុនឡា រួចហើយគន្ធារត់ទៅផ្ទះ ដើម្បីប្រាប់គំនិតទាំងអស់នេះ ទៅឪពុកម្ដាយនាង។

Kunthea continued to explain to Mr. Bunla and Sophy everything that she saw on the farm in Indonesia. Sophy, with a growing smile, just looked at Kunthea and nodded. She was so happy to have her best friend home. Once Kunthea and Sophy said goodbye to Mr. Bunla, Kunthea ran to her house to tell her parents about her idea.





ឪពុករបស់គន្ធាសម្លឹងមុខកូនដោយក្ដីបារម្ភ រួចនិយាយថា៖ ”កូនស្រីពុក! ទីនេះគឺប្រទេសខ្មែរ មិនមែនប្រទេសឥណ្ឌូនេស៊ីទេ។ តើផែនការរបស់កូន អាចដំណើរការឬអត់?”

គន្ធាសម្លឹងមើលកែវភ្នែកឪពុកនាង រួចនិយាយតិចៗ៖ ”ពុក! ដើមឈើនៅតែជាដើមឈើ ទឹកភ្លៀងនៅតែជាទឹកភ្លៀង។ ឥណ្ឌូនេស៊ី និងកម្ពុជា ស្ថិតនៅលើផែនដីតែមួយ។

Her father looked at her with a worried look and said, “My daughter. This is Cambodia, not Indonesia. How do you know your plan will work?” Kunthea whispered as she stared at her father’s big brown eyes. “Father, trees are trees and rain is rain. Indonesia and Cambodia share the same planet.





អ្វីដែលខុសគ្នា គឺវិធីដែល
យើងថែទាំព្រៃឈើ សត្វព្រៃ សត្វចិញ្ចឹម
ដែលរួមមានទាំងហ្វូងគោផងដែរ!” ឪពុកនាងឮដូច្នោះ
ក៏ឱនមកឱបកូន ហើយតបថា៖ ”កូននិយាយត្រូវហើយគន្ធា! អ្វីដែល
ធ្វើឲ្យយើងផ្លាស់ប្តូរ គឺចេញពីរបៀបដែលយើងថែរក្សាបរិស្ថាន និងទីកន្លែង រស់
នៅរបស់យើង។ តោះនាំយកព្រៃឈើរបស់យើងពីមុនត្រឡប់មកវិញ!”

The difference is how we care for our plants, trees, wildlife and all animals, including our cows!” Her father bent down and hugged his daughter. “You are right Kunthea. It is how we care for our home that makes us different. Let’s bring back our home.”



ថ្ងៃបន្ទាប់ គន្ធានិងសូភី បានទៅជួប ពូប៊ុនឡា ដើម្បីឲ្យគាត់ជួយរៀបចំផែនការ ដាំដើមឈើសម្រាប់សាន់នី
និងស្មៅបៃតងសម្រាប់ចម្ប៉ាព្រមទាំងមិត្តភក្តិរបស់វា។ ”លោកពូ ប៊ុនឡា!” គន្ធាស្រែកហៅពីក្រៅ
ផ្ទះឈើរបស់គាត់។ ”តើលោកពូអាចជួយពួកយើងដាំដើមឈើឡើងវិញបានដែរឬទេ?”

The next day, Kunthea and Sophy went to see Mr. Bunla to ask him to help create a plan that included trees for Mr. Sunny and green plants for Mr. Champa and all his friends. "Mr. Bunla!" shouted Kunthea from outside his wooden house. “Can you help us grow a forest?”



ពូប៊ុនឡាកំពុងឈរក្បែរបង្អួច ច្រៀងដាក់ផ្កាដែលព្យួរក្នុងផ្ទះរបស់គាត់ ក៏ងាកទៅរកគន្ធារួចនិយាយថា៖ ”ពូអាចជួយបាន ហើយពូនឹងជួយក្មួយក្នុងការដាំដើមឈើ ឲ្យក្លាយទៅជាព្រៃឈើ សម្រាប់សត្វទាំងតូច ទាំងធំ ច្រៀងរាំ លេងសប្បាយ ពីព្រឹកដល់ល្ងាច។” ឮដូចនេះ គន្ធាសប្បាយចិត្តណាស់ក៏លោតឡើងលើយ៉ាងខ្ពស់ផុតពីដី ធ្វើឲ្យនាងមានអារម្មណ៍ថាស្ទើរតែអាចហោះបានទៅហើយ។ នាងចាប់ផ្តើមគិតថា សាន់នី វានឹងត្រឡប់មករស់នៅលើភ្នំ ក្នុងស្រុកសំឡូត ជិតចម្ការគន្ធាវិញហើយ។

Mr. Bunla was standing by his open window and singing to all the flowers that were growing in and on his house. He turned to face Kunthea and said, “I can and I will help you grow a forest. A forest so full of trees that all the animals in the kingdom will want to sing, dance and play from morning till night!” Kunthea was so happy. She jumped so high she felt that she could almost fly. She started to think about Mr. Sunny and how he would return to his home in the Samlout hills overlooking Kunthea’s family farm.





ខណៈពេលដែលពូប៊ុនឡា ចេញទៅជួបគន្ធានិងសូភីនៅខាងក្រៅផ្ទះ គន្ធាឈប់ទ្រឹង ហើយប្រែទឹកមុខជាក្រៀមក្រំ។ ពូប៊ុនឡាសួរទៅគន្ធា៖ ”មានរឿងអ្វីគន្ធា? ក្មួយមិនសប្បាយចិត្តទេឬ យើងនឹងដាំដើមឈើឡើងវិញហើយតើ?” គន្ធាឆ្លើយតបតិចៗ៖ ”ចាសពិតហើយ! ចម្ប៉ាវានឹងសប្បាយនៅពេលបានជួបសាន់នីម្តងទៀត ប៉ុន្តែខ្ញុំបារម្ភពីសុខភាពរបស់វា។ វាមើលទៅស្គមខ្លាំងណាស់។ ខ្ញុំចង់ឲ្យវារីករាយហើយនិងមានសុខភាពល្អ។”

As Mr. Bunla went to meet Kunthea and Sophy outside, Kunthea stopped dancing and looked very sad. “What’s wrong, Kunthea? Aren’t you happy we will grow a forest?” asked Mr. Bunla. “Yes. I am," whispered Kunthea. "But what about Mr. Champa? He will be so happy to see Mr. Sunny, but I’m a little worried about his health. He looks so skinny. I want him to be happy and healthy.”





ពូប៊ុនឡាសម្លឹងគន្ធាហើយយកដៃទះស្មានាងតិចៗ រួចនិយាយថា៖ ”គន្ធា! ពូទើបតែរៀនអំពីប្រភេទស្មៅថ្មីដែលសំបូរទៅដោយប្រូតេអ៊ីន និងសារធាតុចិញ្ចឹម ហើយវាមានសារៈសំខាន់សម្រាប់គោផងដែរ។” និយាយរួចគាត់ក៏ហៅ “មកនេះ! ពូនឹងបង្ហាញក្មួយ!“ គន្ធានិងសូភី ក៏ប្រញាប់ទៅតាម ពូប៊ុនឡាទៅកាន់រោងពណ៌បៃតងដ៏ធំក្នុងកន្លែងបណ្តុះកូនឈើ។ នៅទីនោះ គន្ធាបានឃើញរូបភាពដែលបង្ហាញពីគោ មានធំ មានតូច មានស្គម មានធាត់។ ខ្លះពណ៌ត្នោត ខ្លះមានលាយពណ៌ខ្មៅ។ នាងក៏ឃើញប្រភេទស្មៅខុសៗគ្នាជាច្រើន ព្យួរលើជញ្ជាំង។ គន្ធាលាន់មាត់ភ្ញាក់ផ្អើល៖ “អស្ចារ្យណាស់! ទាំងនេះធ្វើឲ្យខ្ញុំនឹកឃើញកាលសូភីបានបង្ហាញពួកយើង នូវសួនបន្លែព្រមទាំងសារៈសំខាន់សម្រាប់យើងក្នុងការញ៉ាំបន្លែ។”

Mr. Bunla looked at Kunthea and patted her on the shoulder. “Kunthea, I just learned about these new green grasses that are rich in protein and nutrients and are very good for cows. Come. I will show you.” Kunthea and Sophy eagerly followed Mr. Bunla to a very big and very green room inside his tree nursery. Inside the room Kunthea saw colourful pictures of many cows - big and small, fat and thin; some with brown spots and some with black ones. She also saw different types of grasses on the wall. “Wow!” cried Kunthea, “This reminds me of when Sophy showed us the veggie gardens and how important it was for us to eat veggies.”

ពូប៊ុនឡាតប៖ ”ត្រូវហើយ! គោក៏ត្រូវការ ការថែទាំ ហើយនិងអាហារដែលធ្វើឲ្យមានសុខភាពល្អដែរ។ ត្រូវចាំថា គោទាំងនោះក៏ទទួលអារម្មណ៍ដឹង ដូចជាយើងដែរ។ ពួកវាត្រូវការស្មៅបៃតងដែលសំបូរដោយប្រូតេអ៊ីន និងសារធាតុចិញ្ចឹមផ្សេងៗទៀត។ ស្មៅទាំងនេះគឺងាយស្រួលដាំ មើលថែ ហើយក្មេងៗនិងឪពុកម្តាយរបស់យើងក៏ងាយស្រួលក្នុងការរក្សាទុកដែរ។ មិនតែប៉ុណ្ណោះ វាក៏មិនត្រូវការទឹកច្រើន ហើយជួយដីទៀតផង។” គន្ធាសួរ៖ ”តើវានឹងជួយដីយ៉ាងដូចម្តេចទៅ?” ពូប៊ុនឡាតប៖ ”វាជួយផ្តល់នីដ្រូសែនទៅឲ្យដីធ្វើឲ្យដីមានជីវជាតិសម្រាប់ការលូតលាស់របស់រុក្ខជាតិដំទែ។”

“Yes!” said Mr. Bunla. “Cows also need to eat a healthy diet and receive lots of care. Remember! They have feelings just like us. They need green grasses that are rich in protein and other nutrients. These grasses are easy to plant and easy for children and parents to keep. And! They don’t need much water. They will also help the soil.” “How?” asked Kunthea. Mr. Bunla explained how the grasses would put back nitrogen into the soil. The nitrogen would help keep the soil healthy so plants could continue to grow.





ក្រោយពីគន្ធានិងសូភី បានទទួលព័ត៌មានពីពូប៊ុនឡា ពួកនាងក៏ទៅជួបយ៉ូរ៉ានី ដែលជាមិត្តម្នាក់ទៀតនៅក្នុងភូមិ។ យ៉ូរ៉ានីបានបង្រៀនគន្ធា ពីរបៀបបែងចែកសត្វល្អិតមានប្រយោជន៍ និងសត្វល្អិតគ្មានប្រយោជន៍ នៅក្នុងចម្ការរបស់ពួកគេ។ សត្វល្អិតដែលមានប្រយោជន៍ អាចស៊ីពួកសត្វល្អិតដែលគ្មានប្រយោជន៍ ហើយថែមទាំងជួយការពារដំណាំរបស់ពួកគេដោយពុំចាំបាច់ប្រើសារធាតុគីមីដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពទៀតផង។

Once Kunthea and Sophy collected all the information from Mr. Bunla, they went to see Jorani, their other village friend who had taught Kunthea how to separate the good bugs from the bad bugs on their farm. The good bugs were important because they could eat the bad bugs and help protect their crops without using the bad chemicals that can hurt your health.



ពួកនាងទាំងបីក៏បានទៅជួបលោកគ្រូណារ៉ប ដែលជាគ្រូបង្រៀននៅសាលារបស់ពួកគេ។ គាត់យល់ព្រមជួយ គន្ធា សុភី និងយ៉ូរ៉ានី ដើម្បីដាំដើមឈើក្នុងព្រៃឲ្យមានពណ៌បៃតងឡើងវិញ។ ដោយសារតែវាជាវិស្សមកាល លោកគ្រូណារ៉បបានស្នើសុំឪពុកម្តាយ និងសិស្សរបស់គាត់ ទៅជួយដាំដើមឈើនៅលើភ្នំ ហើយនិងស្មៅ សម្រាប់គោនៅក្នុងភូមិរបស់ពួកគេ ជាពិសេស ចម្ប៉ា។ អ្នកភូមិគ្រប់គ្នា ទាំងចាស់ទាំងក្មេង បានយកធុង ប៉ែល ចបជីក ចបកាប់ ដើម្បីដាំដើមឈើនៅលើភ្នំសំឡូត។

The three girls also went to see Mr. Narap, the village teacher at their school. Mr. Narap agreed to help Kunthea, Sophy and Jorani plant their green forest. Because it was the summer break, Mr. Narap asked all the parents and his students to help plant trees on the hills and some green grasses for the village cows, especially for Mr. Champa. Villagers, young and old, gathered on the Samlout hills with their shovels, buckets and hoes.





ជារៀងរាល់ថ្ងៃ ពួកគេព្យាយាមស្វែងរកទឹកពីក្នុងភូមិសម្រាប់ស្រោច និងដាំកូនឈើ ទាំងតូចទាំងធំ ហើយនឹងមានពេលដើម្បីមើលថែទាំវា ជាប្រចាំទៀតផង។ ហ្វូងគោបានមើលមកពួកអ្នកភូមិ ដែលប្រឡាក់ខ្លួនស្រមក។ ពួកវាស្រែកម៉ូៗដាក់គ្នាសួរថា ″តើមានរឿងអ្វីកើតឡើង?″ ចម្ប៉ាឈរយ៉ាងមានមោទនភាព វាស្រែកម៉ូៗដាក់មិត្តភក្តិរបស់វាថា “គន្ធា និងមិត្តភក្តិដ៏ទៃទៀតរបស់នាងបានរៀបចំផែនការ នាំយកព្រៃឈើត្រឡប់មកវិញហើយ ថែមទាំងដាំស្មៅបៃតងសម្រាប់ជាចំណីរបស់ពួកគេយ៉ាងពិសេសទៀតផង។”

Every day they collected as much water as they could find across the entire village to plant trees, big and small, and then took their time to care for them all. The village cows looked at the villagers covered in dirt and dust, and mooed mooed to each other to ask, “What is this about?” Mr. Champa, standing tall and proud, mooed to his friends that Kunthea and her friends had a plan. He mooed about the forest and the special green grasses that could feed them all.





បន្ទាប់ពីបានដាំដើមឈើលើភ្នំ និងដាំស្មៅក្នុងចម្ការ ជាច្រើនសប្តាហ៍ជាមួយអ្នកភូមិកន្លងផុតទៅ គន្ធា សូភី និងយ៉ូរ៉ានី សម្រេចចិត្តនាំគ្នាទៅអង្គុយលេងនៅក្រោមដើមឈើដ៏ធំមួយក្នុងចម្ការរបស់គន្ធា។ ពួកគេសប្បាយរីករាយជាងជ្រូកប្រលែងលេងក្នុងភក់ទៅទៀត ក៏នាំគ្នាសម្រាកកាយ ហើយសម្លឹងមើលទៅចម្ប៉ា ដែលកំពុងតែឈរមើលកន្លែងដាំស្មៅថ្មី មុននឹងដើរហួសទៅផឹកទឹកពីក្នុងស្នូកថ្មីរបស់វា។ ចម្ប៉ាងើបក្បាលមើលទៅគន្ធា សូភី និង យ៉ូរ៉ានី ហើយស្រែកឮៗយ៉ាងពិរោះថា ម៉ូៗ.... អរគុណដល់ពួកនាង។

After many weeks of planting trees on the hills and grasses on the farms with the villagers, Kunthea, Sophy and Jorani, decided to go to Kunthea's family farm and sit under the family's spirit tree. Happier than the village pigs playing in mud, they relaxed and watched Mr. Champa inspect his new green garden and walk over to drink water from his new water well. Mr. Champa lifted his head towards the girls and gave them a loud and sweet sounding Moo Moo...Thank You.....





## មួយឆ្នាំក្រោយមក...

សំឡេងទឹកភ្លៀងច្រើនលានតំណក់ ធ្លាក់ខ្លាំងៗលើដំបូលស័ង្កសីរបស់ ផ្ទះគន្ធា ធ្វើឲ្យនាងរត់ចេញមកខាងក្រៅ។ វាជាដើមខែមករាហើយ ភ្លៀងចាប់ផ្ដើមធ្លាក់ស្រោចស្រពមកលើភូមិរបស់នាង។ ដើមឈើមួយចំនួនដែលដាំលើភ្នំកាលពីឆ្នាំមុន ចាប់ផ្ដើមធំលូតលាស់បណ្ដើរៗ។ រីឯស្មៅបៃតងនៅចម្ការរបស់ពួកគេ មើលទៅមានលក្ខណៈស្រស់បំព្រង ដែលអាចផ្ដល់ជាចំណីគ្រប់គ្រាន់សម្រាប់ហ្វូងគោ តាំងពីព្រឹករហូតដល់ល្ងាច ហើយហ្វូងគោទាំងនោះក៏ទទួលបាននូវការមើលថែទាំយ៉ាងកក់ក្ដៅផងដែរ។

## Next year...

The sounds of a million raindrops hitting the tin roof made Kunthea run outside. It was the month of January and the rain had started to fall on their village. The little trees on the hills were starting to grow, and the green forages around the family farm gave quite a good show. The village cows had plenty to eat from morning till night and received many kind hugs with great delight.

ចម្ប៉ាគឺជាគោដែលសប្បាយរីករាយជាងគេក្នុងចំណោមគោទាំងអស់នោះ។ មិត្តសម្លាញ់របស់វា គឺខ្លាឃ្មុំសាន់នី ក៏បានត្រឡប់មកនៅក្នុងព្រៃបៃតងដែលជាផ្ទះរបស់វាវិញ។ ពួកវាទាំងពីរនាក់រត់លេងសប្បាយរីករាយជាមួយនឹងសំឡេងសត្វព្រៃជាច្រើន ដែលហាក់បីដូចជាតន្ត្រី ប្រគុំដ៏អស្ចារ្យ ក្នុងព្រៃសំឡូត៕



Mr. Champa was the happiest cow of them all. His best friend, Mr. Sunny the bear, had finally returned to his home in the green forest. Together they walked, talked and danced to the sounds of Samlout's extraordinary wildlife chorus.



## អំពីសៀវភៅរឿង គន្ធា និង គោរីករាយ

សៀវភៅរឿងគន្ធា និង គោរីករាយ គឺជាសមិទ្ធផលនៃការខិតខំរួមគ្នាជាលក្ខណៈអន្តរជាតិ។ ខណៈពេលដែល បណ្ឌិត ហ្វ្រេន ខូវលី ព្រមទាំងក្រុមការងារនៅសាកលវិទ្យាល័យញូវអ៊ីងឡេន ( University of New England ) បានធ្វើអោយសៀវភៅអាចលេចចេញជារូបរាងបាន ចំណែកឯមិត្តភក្តិជាទីស្រឡាញ់របស់ខ្ញុំគឺ អ្នកស្រី វិនឌី ម៉ាដធ្យូ ពីប្រទេសកាណាដា និង បណ្ឌិត ស្ទេហ្វានី ម៉ុនហ្គោមឺរី ពីប្រទេសអូស្ត្រាលី ក៏បានផ្តល់នូវការគាំទ្រផ្នែកបញ្ញាស្មារតី និង ការកែសម្រួលដើម្បីឈានទៅដល់គោលដៅនៃការបញ្ចប់សៀវភៅរឿងមួយនេះ។ ពួកគាត់ទាំងពីរ មានបទពិសោធន៍ក្នុងការរស់នៅនាតំបន់ជនបទនៃប្រទេសកម្ពុជា ជាមួយខ្ញុំផងដែរ។ ខ្ញុំសូមថ្លែងអំណរគុណជាខ្លាំង! ហើយខ្ញុំក៏សូមអរគុណទៅ បណ្ឌិត ដារីល សាវែច និង បប់ ម៉ាទីន ដែលជាក្រុមអ្នកវិទ្យាសាស្ត្រដ៏ខ្លាំងពូកែ ដែលបានធ្វើការនៅតំបន់មូលដ្ឋានភូមិភាគពាយព្យនៃប្រទេសកម្ពុជា ហើយបានផ្តល់ការណែនាំផ្នែកស្រាវជ្រាវ វិស័យកសិកម្មដល់រូបខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ ។

សូមអរគុណដល់លោក អ៊ួម ណារ៉ុប អ្នកស្រី យឹម ម៉ានីកា និងក្រុមគ្រូបង្រៀន នៅស្រុកសំឡូត ដែលបានជួយផ្តល់មតិយោបល់ ការណែនាំ និងការគាំទ្របានទាន់ពេលវេលាដែលជាកត្តាចាំបាច់ ធ្វើឲ្យសៀវភៅនេះ អាចដំណើរការបាន។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសទៅដល់ ស្ថាប័នទាំងបីរួមមាន៖

១) មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ដែលបាន ផ្តល់ឱកាសឲ្យខ្ញុំធ្វើការជាមួយក្រុមអ្នកវិទ្យាសាស្ត្រស្រាវជ្រាវអំពីសត្វគោ និងដំណាំ។

២) សហព័ន្ធគ្រូបង្រៀននៅទីក្រុងអង់តារីអូ ប្រទេសកាណាដា (ETFO) បានផ្តល់ ឱកាសឲ្យខ្ញុំធ្វើការជាមួយក្រុមក្មេងៗ និងគ្រូបង្រៀន និង

៣) ស្ថាប័នសេវាឧទ្យានជាតិសហរដ្ឋអាមេរិក (US NPS) បានផ្តល់ឱកាសឲ្យ ខ្ញុំធ្វើការជាមួយ ក្រុមឧទ្យានុរ័ក្សនៅតំបន់ឧទ្យាន ដើម្បីឲ្យកាន់តែយល់ច្បាស់អំពីសារៈសំខាន់នៃសួនបៃតង (ដើមឈើ និងព្រៃឈើ) និងការវិវឌ្ឍន៍នៃរាងកាយប្រកបដោយសុខភាពល្អ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់មូលនិធិម៉ាដក្សចូលីភីត (អ៊ែមចេភី) និងបុគ្គលិកទាំងអស់ដែលបានណែនាំ និងបំផុសគំនិតដល់ខ្ញុំ កំលុងពេលខ្ញុំរស់នៅប្រទេសកម្ពុជា។ ខ្ញុំនឹងមិនអាចបំភ្លេចនូវក្តីស្រលាញ់ និង ចិត្តដ៏សប្បុរសរបស់អ្នកទាំងអស់គ្នាឡើយ។ សូមអរគុណ!

រឿងគន្ធា និងគោរីករាយ ឆ្លុះបញ្ចាំងអំពីកំណើនឡើងនូវការព្រួយបារម្ភជាលក្ខណៈជាតិ និងអន្តរជាតិ អំពីបញ្ហាសុខុមាលភាពសត្វ ផលិតកម្មផ្នែកបសុសត្វ ព្រមទាំងបញ្ហាកាប់បំផ្លាញព្រៃឈើនៅតំបន់អាស៊ីអាគ្នេយ៍។

ស្ទេហ្វាន់ ប៊ុកណា

## A Word about Kunthea and The Happy Cow

Kunthea and The Happy Cow was truly an international collective effort. While Dr. Fran Cowley and the team at University of New England made the book possible, my dear friends Wendy Matthews from Canada and Dr. Stephanie Montgomery from Australia provided the emotional, intellectual and editorial support needed to complete this journey. They also lived the experiences with me in rural Cambodia. THANK YOU! I am also grateful to Dr. Darryl Savage and Dr. Bob Martin; a strong band of scientists who worked the fields in Northwestern Cambodia and guided me through the years of agricultural research.

Mr. Narap Ourm and the teachers in Samlout (Cambodia) made Happy Cow come to life. Their comments and guidance gave depth and meaning. Cambodia's Manika Yim also offered wise and much needed timely support.

I would like to give special thanks to 3 groups: Australian Centre for International Agricultural Research (ACIAR), Elementary Teachers Federation of Ontario (ETFO) and the US National Park Service (US NPS) for being given the opportunities to work in the fields with scientists on cows and crops; in the classrooms and playgrounds with teachers and children; and in parks with rangers to better understand the importance of green spaces (forests and trees) and healthy human development.

I must also sincerely thank the Maddox Jolie-Pit Foundation (MJP) and the amazing people who guided and inspired me during my life in Cambodia. I will never forget your love, kindness and generosity. Merci.

Happy Cow reflects the growing national and international concern about animal welfare, livestock production and deforestation in Southeast Asia.

**Stephan Bognar**
**Author**